# ការសម្ភាសរបស់អ៊ុំស្រី ចន យ៉េន

កៈ អ្នកធ្វើការសំភាសន៍ឈ្មោះ ហេង សុជីវី ខៈ អ្នកត្រូវគេសំភាសន៍ឈ្មោះ ចន យ៉េន

កៈ ចាស!ជាដំបូងសូមជុំរាបសួរអ៊ុំ!

ខៈ ចាស!ហើសៗៗ(គាត់កំពុងតែបានសោចសប្បាយចិត្ត)

កៈ
ចាសអ៊ុំខ្ញុំមកថ្ងៃនេះខ្ញុំមានឱកាសមែនទែនដែលបានមកសំភាសន៍អ៊ុំស្រីផ្ទាល់ហើយខ្ញុំមកពីខាងគំរោងខាងសាលារៀនរបស់ខាងសាលានៅខាងសហរដ្ឋអាមេរិច
ហើយខាងសាលានេះមានគំរោងមួយដើម្បីនឹងធ្វើការសំភាសន៍របស់ប្រជាជនកម្ពុជាអំពីជីវៈប្រវត្តិរបស់គាត់នឹងបទពិសោធន៍ជីវិតរបស់គាត់ហើយនឹងក្រុមគ្រួសាររបស់គាត់ផងដែរហើយការសំភាសន៏មួយនេះនឹងត្រូវបានធ្វើឡើងនៅក្នុងថ្ងៃនេះតែម្តងគឺនៅក្នុងថ្ងៃទី៩នៅក្នុងខែ៦នៅក្នុងឆ្នាំ២០១៨
ហើយអឺខ្ញុំមានឱកាសដើម្បីនឹងធ្វើការសំភាសន៏ដល់អ៊ុំផ្ទាល់ដូចនេះតើអ៊ុំអនុញ្ញាតដើម្បីនឹងអោយខ្ញុំធ្វើការសំភាសន៏ដល់អ៊ុំដែរឬទេ?

ខៈ មានអីហើសៗៗ

កៈ ចាស!ចឹងជាដំបូងនឹងអ៊ុំមានឈ្មោះអ្វីដែរអ៊ុំ?

ខៈ ខ្ញុំមានឈ្មោះថា ចន យ៉េន ។

កៈ ចាស !ចឹងឈ្មោះរបស់អ៊ុំមានឈ្មោះថា អ៊ុំ ចន យ៉េន ហើយអ៊ុំមានឈ្មោះហៅក្រៅដែរឬទេ?

ខៈ អត់មានទេ។

កៈ ហើយចុះឈ្មោះរបស់អ៊ុំនៅក្នុងអត្តសញ្ញាប័ណ្ណអ៊ុំមានឈ្មោះអ្វីដែរ?

ខៈ ខ្ញុំមានឈ្មោះចឹងតែម្តង ដែលឪពុករបស់ខ្ញុំនឹងគាត់មានឈ្មោះថា ចន
ហើយខ្ញុំមានឈ្មោះថា យ៉េន នឹងឯង។

កះ ចាស!ចឹងឈ្មោះពេញរបស់អ៊ុំដែលមាននៅក្នុងអត្តសញ្ញាប័ណ្ណនឹងមានឈ្មោះចឹងតែម្តង?

ខះ នឹងហើយ ។

កះ ហើយឈ្មោះមួយនឹងតើឪពុកម្តាយរបស់អ៊ុំគាត់ជាអ្នកដាក់អោយឬក៏យ៉ាងណាដែរ?

ខះ ចាស!ឈ្មោះរបស់ខ្ញុំនឹងគឺឪពុកម្តាយរបស់ខ្ញុំគាត់ជាអ្នកដាក់អោយខ្ញុំនឹងតែម្តង។

កះហើយតើឈ្មោះនេះមានអត្តន័យយ៉ាងម៉េចដែរអ៊ុំ?

ខះ ដឹងអីខ្ញុំមិនបានដឹងដែរអំពីវាពេលនឹងគាត់ជាអ្នកដាក់អោយចឹងហើយនឹងហាហា

កះ ចាស!ឮអ៊ុំហើយចឹងតើអ៊ុំមានស្រុកកំណើតនៅឯណាដែរអ៊ុំ?

ខះ អ៊ុំមានស្រុកកំណើតនៅទីនឹងតែម្តងនៅនឹងម៉ង់។

កះ តើនៅក្នុងភូមិនឹងឃុំអ្វីដែរ?

ខះ នៅក្នុងភូមិ ខ្ពប ឃុំ ខ្ពប នៅក្នុងស្រុក កោះឧញ្ញាតីយើងននឹង។

កះ ចាស!ហើយចុះអ៊ុំមានអាយុប៉ុន្មានហើយសព្វថ្ងៃនឹង?

ខះ ខ្ញុំមានអាយុ៥២ឆ្នាំទៅ៥៣ឆ្នាំហើយ។

កះ ចាស!ហើយទៅអ៊ុំមានបានចាំថ្ងៃខែឆ្នាំកំណើតរបស់ខ្លួនដែរឬទេ?

ខះ
អត់ទេហាហាមិនបាននឹងចាំទេទាល់តែនៅក្នុងអត្តសញ្ញាប័ណ្ណរបស់ខ្ញុំឯនោះបានមានហីស។

កះ ចាស!ហើយចឹងខ្ញុំអាចសូមមើលនឹងថតអត្តសញ្ញាប័ណ្ណរបស់អ៊ុំបានដែរឬទេ?

ខះ អូ!អត្តសញ្ញាប័ណ្ណមួយនឹងកូនវាយកទៅណាបាត់ហើយនឹង

កះ ចាស!!

ខះ វាពេលនឹងយកទៅទាំងសំបុត្រនឹងសៀវភៅគ្រួសារ នេ
មានទាំងសំបុត្រកំណើតរបស់វានឹងតែម្តងវាបានយកទៅ

ព្រោះអីកាលនឹងវាធ្វើជាទាហានឯនោះដល់ពេលចឹងទៅគេថាធ្វើការដំឡើងសក័អោយទៅវាចឹងហើយវាត្រូវការឯសារចឹងវាក៏យកទៅទាំងអត្តសញ្ញាប័ណ្ណរបស់ខ្ញុំទៅនឹងព្រមទាំងសៀវភៅគ្រួសារដែលទៅបាត់នៅនឹងទៅ។

ក៖ ចាស!ហើយចុះអ៊ុំមានស្រុកកំណើតពីមុនមកនឹងនៅឯណាដែរ?

ខ៖ អត់មានទេនៅឯនឹងផ្ទាល់តែម្តងគឺមានទីលំនៅនៅស្រុននឹងម៉ង់។

ក៖ ចឹងអ៊ុំមានទីតាំងកំណើតនៅនឹងតែម្តង?

ខ៖ ចាស!!

ក៖ ហើយចុះឪពុកម្តាយរបស់អ៊ុំនឹងតើពួកគាត់មានឈ្មោះអ្វីខ្លះដែរ?

ខ៖ ឪពុករបស់ខ្ញុំនឹងគាត់មានឈ្មោះថា ចន ហើយម្តាររបស់ខ្ញុំនឹងក៏មានឈ្មោះថា យ៉ន។

ក៖ ហើយចុះឈ្មោះពេញរបស់ពួកគាត់ទាំង២នាក់មានឈ្មោះអ្វីដែរ?

ខ៖ ចឹងឯឈ្មោះពេញនឹងគ្មានឈ្មោះឯណា២ទេមានឈ្មោះតែមួយៗនឹង។

ក៖ តែឈ្មោះដែលពេញហើយវាជាផ្លូវការណាអ៊ុំមានឈ្មោះនាមត្រកូលនឹងឈ្មោះរស់គាត់។

ខ៖ អូ! ឈ្មោះនាមត្រកូលរបស់គាត់អី?

ក៖ ចាស!!

ខ៖ ម៉ែខ្ញុំនឹងគាត់មានឈ្មោះនាមត្រកូលរបស់គាត់គឺមានឈ្មោះថាហាម
ចឹងឈ្មោះគាត់ពេញគឺឈ្មោះ ហាម យ៉ន
ហើយឯចំណែកម្តាយរបស់ខ្ញុំវិញនឹងគាត់មាននាមត្រកូលថា ឯក ចឹងទៅជាឈ្មោះពេញនឹងគឺឯក យ៉ន។

ក៖ ចាស !ហើយអឺ ចឹងសព្វថ្ងៃនឹងអ៊ុំមានក្រុមគ្រួសារហើយ?

ខ៖ មានហើយ

ក៖ ចឹងអ៊ុំមានក្រុមគ្រួសារនឹងចឹងតើអ៊ុំមានកូនបានប៉ុន្មាននាក់ដែរ?

ខ៖ ខ្ញុំមានកូនដល់ទៅ៥នាក់។

ក៖ ចាស!ចឹងតើពួកគាត់មានឈ្មោះអ្វីខ្លះទៅអ៊ុំ?

ខ៖ កូនមួយនោះនឹងវាជាកូនបងគេឈ្មោះសុខ លី ហើយសុខ លីហើយទៅ
កូនមួយទៀតនឹងគឺ សុខ ឡេង ហើយ សុខ លាង សុខ ខេង សុខ យៀង។

ក៖ ចាស !ហើយទៅគាត់ប្រុសប៉ុន្មាននាក់ហើយស្រីប៉ុន្មាននាក់ដែរ?

ខ៖ ប្រុសមាន៤ស្រីមានតែ១។

ក៖ ហើយពួកគាត់បានរៀបអាពាហ៍ពិពាហ៍នឹងបានប៉ុន្មានក្រុមគ្រួសារហើយ?

ខ៖
គេមានគ្រួសារអស់ហើយឥឡូវនឹងនៅមានតែកូន២នាក់ទេដែលមិនទាន់មានក្រុមគ្រួសារនៅ
កូនប្រុសៗនឹង២នាក់នឹង។

ក៖ ចាស!ហើយអ៊ុំអឺ អ៊ុំមានបងនឹងប្អូននៅខាងក្រៅប្រទេសដែរឬទេ?

ខ៖ អត់មានទេ អត់មានផង។

ក៖ ហើយចុះអ៊ុំមានការសិក្សាដល់កំរិតណាដែរអ៊ុំ?

ខ៖ ខ្ញុំនឹងនិយាយទៅនឹងខ្ញុំបានរៀននៅថ្នាក់ទី៤បានត្រឹមនឹងកាលជំនាន់នឹងកាលពីជំនាន

ពពត។

ក៖ អូអ៊ុំបានរៀនត្រឹមថ្នាក់ទី៤
ចឹងកាលសម័យនឹងតើគេបានរៀនដល់កំរិតណាដែលបើប្រៀបធៀបនឹងសម័យនេះ?

ខ៖ អត់បានដឹងទេ
ព្រោះកាលនឹងអ៊ុំរៀននឹងវាបានគួរសមដែរនឹងវាមិនទៅដល់ថ្នាក់វាល្ងង់ពេកហីសៗ

ក៖ ចឹងអ៊ុំអាចនឹងធ្វើការសរសេរនឹងអានបាន?

ខ៖ អ៊ុំអាចធ្វើការសរសេរនឹងធ្វើការអានបានចាស។

កៈ ចាស!ចឹងអ៊ុំបានចេះបានប៉ុន្មានភាសាដែរ?

ខៈ អ៊ុំចេះតែភាសាខ្មែរយើងនឹងហាហាហា

កៈ ហើយទៅកាលនឹងអ៊ុំបានរៀននៅក្នុងសាលាណាដែរ?

ខៈ រៀននៅក្នុងសាលាវត្តយើងនឹងវត្តនៅកោះ។

កៈ វត្តកោះតើអ៊ុំមានបានចាំឈ្មោះរបស់ពួកគាត់ដែរឬទេ?

ខៈ វត្តនឹងមានឈ្មោះថាវត្តក្បាលកោះ។

កៈ
ចាស!ហើយបន្ទាប់មកអ៊ីតើអ៊ុំបានសិក្សានឹងបានរៀនត្រឹមថ្នាក់ទី៥ហើយអ៊ុំបានឈប់រៀនតែម្ដង?

ខៈ
ចាស!ឈប់ទៅបើមានឯណាកាលនឹងក្រុមគ្រួសារនឹងម៉ែរបស់ខ្ញុំនឹងកាលនឹងជាមួយនឹងឪពុករបស់ខ្ញុំនឹងពេលនឹងវាអត់មានកូនចៅឯណាទៀតពេលនឹងមានតែខ្ញុំនឹងវាធំជាងគេដែលត្រូវទៅរកស៊ីសំរាប់ប្អូនៗ៣នាក់នឹងដើម្បីអោយវាបានទៅរៀនណំទៅបានហើយវាបានបែកទៅមានក្រុមគ្រួសារទៅអីចឹងទៅ ហើយពេលនឹងមានតែខ្ញុំនឹងទេដែលមានវ័យធំជាងគេ។

កៈ ចាស!ចឹងមូលហេតុដោយសារតែប៉ុណ្ណឹងទេណំអ៊ុំណំបានធ្វើអោយអ៊ុំឈប់រៀន?

ខៈ ចាសនឹងហើយបាន បានជាអ៊ុំវាមិនបានរៀនបានជ្រៅជ្រះនឹងគេ
គេកាលនឹងម៉ែឪពុករបស់ខ្ញុំកាលនឹងគឺគាត់វាក្រចឹងហើយកាលនឹងពួកគាត់នឹងគ្មានអ្វីដើម្បីនឹងតស៊ូអោយកូនបានរៀននោះទេដើម្បីនឹងធ្វើការរៀនបន្តទៅទៀតនោះទេ
គាត់បានស្ដាយដែលតើថាពេលនឹងខ្ញុំនឹងវារៀនទៅនឹងវារាងប្រាជ្ញ
ហើយពេលនឹងដំពេលដែលគាត់អត់ចឹងទៅហើយពេលនឹងឪពុករបស់ខ្ញុំនឹងគាត់ឈឺចឹងហើយពេលនឹងគឺគាត់មានជំងឺឈឺនឹងគឺជំងឺរបែងផង។

កៈ
ចាស!ហើយទៅចឹងកាលនឹងតើអុំបានចាប់អារម្មណ៍ទៅលើដែលពេលនឹងអុំនឹងគិតថាកាលនឹងធ្វើអោយអុំមានចំណាប់អារម្មណ៍ចង់រៀនហើយធ្វើអោយអុំចង់ចាំមកដល់សព្វថ្ងៃនឹង?

ខៈ កាលនឹងដូចជាគ្មានបានជាគិតគូរអីប៉ុន្មាននោះទេកាលនឹងនិយាយអោយត្រង់ទៅ
និយាយទៅនឹងយើងនឹងដូចថាពេលនឹងវាក្រវាអត់ចឹងណា
ចឹងហើយក៏មិនបាននឹងចាប់អារម្មណ៍នឹងមុខវិជ្ជាអ្វីទេ។

កៈ ចាស!!

ខៈ ហើយក៏គ្រាន់តែរៀនបានតែមួយចេះៗទៅ។

កៈ ចាស!ហើយសព្វថ្ងៃនឹងតើអុំមានមុខរបរជាអ្វីដែរ?

ខៈ ខ្ញុំនឹងធ្វើការងារត្បាញរវៃនឹង ។

កៈ ជាអ្នកខាលសូត្រណំអុំណំ?

ខៈ ចាស!!

កៈ ហើយអឺ
ចឹងការងារមួយនឹងអុំបានធ្វើបានប៉ុន្មានឆ្នាំហើយដូចថាអុំបានមានបទពិសោធន៍ធ្វើជាមួយនឹងវានឹងបានប៉ុន្មានឆ្នាំហើយអុំ?

ខៈ
ការងារមួយនឹងខ្ញុំបានធ្វើយូរមកហើយដូចថាកាលនឹងខ្ញុំបានធ្វើតាំងពីខ្ញុំមានអាយុបាន១៨ឆ្នាំហើយឥឡូវនឹងខ្ញុំមានអាយុបានជាង៣០ហើយ។

កៈ ចាស!ចឹងអុំមានបទពិសោធន៍ច្រើនឆ្នាំមកហើយចឹង។

ខៈ ចាសៗ

កៈ ចាស!!

ខ៖
ព្រោះអីកាលនឹងយើងគ្មានមុខរបរអីគ្មានការងារអ្វីចឹងក៏ចេះតែធ្វើទៅធ្វើមុខរបរនឹងទៅតែឥឡូវនឹងវាបានគ្រាន់ជារីកចំរើនជាងមុនមកបន្តិចដែរព្រោះអីរបស់របរនឹងវារាងថោកនៅនឹងចឹងទៅហើយដល់នេះចឹងទៅខ្ញុំបានធ្វើខ្លួនឯងហើយខ្ញុំបានទិញមកទុក
ហើយយើងមានដើមទុកចឹងហើយក៏យើងចេះតែធ្វើខ្លួនឯងចឹងតិចតួចចឹងទៅ
រួចយើងបានយកទៅលក់ខ្លួនឯងចឹងទៅបានជាយើងវារាងគ្រាន់បើជាងយើងបានយកវាទៅលក់អោយពួកឈ្មួញកណ្ដាល។

ក៖ ចាស!ចឹងអ៊ុំសព្វថ្ងៃនឹងអ៊ុំបានទិញមកពីណាដែរ?

ខ៖ ចាស?

ក៖ អីវត្ថុធាតុដើមទាំងអស់នឹងអ៊ុំមានបានទិញមកពីណាដែរ?

ខ៖
ខ្ញុំបានទិញមកពីភ្នំពេញនឹងឯង។ព្រោះអីវាក្រនឹងវាបានឆ្អែកឆ្អន់ហើយតាំងពីមុនមកនឹងនិយាយតាមត្រង់ទៅបើនិយាយអំពីរដ្ឋកម្ពុជាវិញកូនខ្ញុំផងនឹងគេបានទៅចាប់ធ្វើទាហានឡើងប្រជាតប្រជីន ដូចជាប្ដីខ្ញុំនឹងគេចាប់ទៅហើយពេលនឹងមិនបាននឹងដេកលើផ្ទះបានស្រួលនោះទេបានដេកតែនៅលើទរទឹកព្រោះអីខ្លាចគេចាប់ទៅធ្វើជាទាហាននោះហើសៗ
វាមិនបានស្រួលនោះទេបានទឹមតែបានមកឥឡូវនោះទេ។

ក៖ ចាស!ហើយទៅអ៊ុំដូចថាអ៊ុំបានរៀបការជាមួយនឹងលោកពូនឹងបានប៉ុន្មានឆ្នាំហើយ?

ខ៖ ចាស?

ក៖ ដូចថាអ៊ុំបានរៀបការជាមួយនឹងលោកពូបានប៉ុន្មានឆ្នាំហើយ?

ខ៖ ខ្ញុំ ខ្ញុំបានការនឹងតាំងពីនៅក្នុងឆ្នាំ១៩៨១។

ក៖ ចាស
!ហើយកាលនឹងអ៊ុំបានស្រលាញ់គ្នាជាមួយនឹងលោកពូឬក៏អ៊ុំដោយសារតែឪពុកម្ដាយពួកគាត់បាននឹងរៀបការអោយ?

ខ៖ ហ៊ីស!
កាលនឹងឪពុកម្តាយរបស់ខ្ញុំនឹងគាត់គឺជាអ្នករៀបចំអោយចឹងព្រោះអីកាលនឹងគាត់នឹងនៅឯណានោះសោះពួកខ្ញុំនឹងមិនដែលបានស្គាល់គ្នាសោះតែម្តងហាហា
មិនដូចជាក្មេងសព្វថ្ងៃនេះទេដែលគេបានទាក់ទងគ្នាចឹងទៅក៏បានការហាហាអត់ទេ
ក្មេងសព្វថ្ងៃនឹងវាស្រួលវាស្រួលណាស់មិនចេះតែថានោះតែកាលខ្ញុំនោះនឹងខ្ញុំមិនដែលបានស្គាល់គ្នាសោះខ្ញុំមិនបានចេះតែថានោះទេ។

ក៖ ចាស!ហើយចុះកាលដែលអ៊ុំបានការនឹងនៅក្នុងសម័យក្រោយពពតឬក៏នៅមុនពពត?

ខ៖ កាលនឹងបានចប់សម័យពពតនឹងហើយបានចប់ហើយ។

ក៖ ចាស!បានចប់ហើយ។

ខ៖ នឹងហើយកាលនឹងយើងបានចប់នឹងមិននៅក្នុងសម័យឆ្នាំ១៩៧៨នឹង១៩៧៩អី?

ក៖ ចាស!នៅឆ្នាំ១៩៧៩។

ខ៖ ចាស!នឹងហើយកាលដែលខ្ញុំបានការនឹងនៅក្នុងឆ្នាំ១៩៨១។

ក៖ ហើយដល់ពេលចឹងអ៊ុំបានរៀបការជាមួយនឹងលោកពូនឹងតើគាត់មានឈ្មោះអ្វីដែរទៅអ៊ុំ?

ខ៖ គាត់មានឈ្មោះថា សយ។

ក៖ តើគាត់មានស្រុកកំណើតនៅឯណាដែរទៅ?

ខ៖ គាត់មានស្រុកកំណើតនឹងនៅក្នុងស្រុកឯព្រះវិហារសួគ៍ឯនោះ
អីអាស្រឡុននៅវិហារសួគ៍ឯនោះនាងមិនស្គាល់ទេ។

ក៖ នៅឆ្ងាយពីទីនេះ?

ខ៖ នៅឆ្ងាយតើ។

ក៖
ហើយចឹងពេលដែលបានរៀបអាពាហ៍ពិពាហ៍នៅក្នុងសម័យជំនាន់នឹងតើគេធ្វើបែបណាដែលដូចជាខាងប្រុសគេមកចូលស្តីដណ្តឹងមុនហើយទៅបានជាគេរៀបការ?

ខ៖ នឹងហើយចាស

ក៖ ចឹងកាលនឹងវាមានលក្ខណៈបែបធម្មតា?

ខ៖ ចាស!!

ក៖ ហើយកាលនឹងវាមិនសូវជាខុសគ្នាទេនេសអ៊ុំ?

ខ៖
វាខុសគ្នាតែត្រង់ថាកាលពីមុននឹងភាគច្រើននឹងម៉ែឪគេជាអ្នករៀបចំអោយតែដល់ពេលឥឡូវនឹងក្មេងៗនឹងវាបានរៀបចំសំរាប់ខ្លួនរបស់វាទៅហើយនឹងបានជាអោយម្ដាយឪរបស់វានឹងចឹងហាហាយើងមិនបានដឹងទេហាហាហា

ក៖
ចាសចឹងបន្ទាប់មកនឹងអ៊ុំមានបានដឹងទេថាអ៊ុំមានបងនឹងប្អូនដែលពួកគាត់បានស្លាប់នៅក្នុងសម័យពពតដែលឬទេអ៊ុំ?

ខ៖
អូខ្ញុំមានបងនឹងប្អូនដែលបានស្លាប់ទៅនឹងរហូតដល់ទៅ៣ទៅ៤នាក់ឯនោះបងប្អូនរបស់ខ្ញុំនឹងគេបានស្លាប់នឹងនោះកាលនៅក្នុងសម័យជំនាន់ពពតនឹងមានចំនួនដល់ទៅ៤នាក់ ។

ក៖ ចាស!!

ខ៖ មានបងប្អូនមួយនឹងគេបានធ្វើជាកម្មាធិបាល គេក៏យកគាត់ទៅវៃចោលអស់រលីង។

ក៖ ហើយកាលនឹងអ៊ុំមានអាយុប៉ុន្មានហើយកាលនឹង?

ខ៖
អូកាលនឹងខ្ញុំមានអាយុអឺកាលនៅក្នុងសម័យពពតនឹងខ្ញុំទឹមតែមានអាយុ១៣ឆ្នាំទៅ១៤ឆ្នាំនឹង ។

ក៖ ចឹងកាលនឹងតើអ៊ុំមានបានទាន់ពួកគាត់ស្លាប់ដែលឬទេកាលនឹង?

ខ៖ ចឺមិនដឹងកាលនឹងតែមិនបានដឹងថាគាត់នឹងស្លាប់នៅឯណា។

គ៖ ដឹង១១១

ខ៖
ដឹងថាគាត់នឹងបានស្លាប់តែមិនបានដឹងថាគេយកគាត់ទៅសំលាប់ចោលនៅឯណាព្រោះអីកាលនឹងគេបានត្រឹមតែមកជូនដំណឹងយើងថាគាត់បានគេយកទៅសំលាប់ហើយស្លាប់បាត់ទៅហើយ
បើបានដឹងនឹងគឺមានបងមួយនឹងគាត់ស្លាប់នៅស្នែងលួសយើងនឹងព្រោះអីពេលនឹងគាត់មានជំងឺគ្រុនចាញ់។

ក៖ ចឹងមានន័យថាក្រៅពីនឹងពួកគាត់បានបាត់ដំណឹង?

ខ៖
នឹងហើយបានបាត់ដំណឹងសូត្រឈឹងមានបានមកផ្ទះមកសំបែងអីទេកាលនៅក្នុងសម័យជំនាន់អាពតនឹងនោះ។

ក៖
ចុះចឹងអ៊ុំមានចង់ប្រកាសស្វែងរកដំណឹងបាត់បងនឹងប្អូនដែរឬទេ?ឬក៏អ៊ុំគិតថាគាត់គ្មានជីវិតទេគឺគាត់បានអនិច្ចកម្មបាត់បង់ជីវិតបាត់ទៅហើយ?

ខ៖ វាពិបាកណា
បើមានបងមួយនោះគេថាគាត់នៅឯណានោះទេនៅឯណានោះទេគេខ្លះទៅថាគាត់នៅឯស្រុកម៉ាឡេ ហើយខ្លះទៅថាគាត់ទៅនៅឯណាក៏បាត់ទៅ
តែខ្ញុំបាននឹកឃើញថាវាយូរហើយបើគាត់នឹងមានជីវិតនឹងគាត់នឹងធ្វើការស្វែងរកម្ដាយឪពុករបស់គាត់ហើយតែវាយូរហើយគាត់មិនដែលបានមករកតែគាត់មិនដែលបានលឺថាមិនរកអីផងបើគាត់នៅរស់នឹងពិតជាគាត់នឹងធ្វើការស្វែងរកម៉ែឪពុករបស់គាត់ហើយមែនអត់ ជឿអត់?
ខ្ញុំជឿថាចឹង។

ក៖ ចាស!ចឹងឪពុកម្ដាយរបស់អ៊ុំនឹងតើគាត់នៅមានជីវិតដែលឬទេ?

ខ៖ គាត់ស្លាប់អស់ហើយ?

កៈ
ហើយកាលនឹងអ៊ុំមានដូចជាការបន្សុសទុកនូវដូចជារូបថតនឹងខោអាវអីសំរាប់ទុកជារបស់គាត់ដែរភ្លាប់មានដែរឬទេ?

ខៈ
ដូចជារូបថតអីនឹងធ្លាប់មានតើទេឥឡូវនឹងមិនដឹងបានយកទៅទុកនឹងបាត់ទៅណាអស់នោះទេ
ពេលនឹងនៅមានរូបថតរបស់អ៊ុំខ្ញុំមួយនឹងដែលគាត់បានរៀនចប់ហើយនឹងណាកាលនឹងគាត់បានរៀនចប់តែម្តង
ហើយពេលនឹងកាលដល់ជំនាន់ពពតនឹងគេថាអោយគាត់ទៅធ្វើស្មីទេដូចថាដល់ពេលមួយជំនាន់មកទៀតនឹងពួកវានឹងបានគៀលមនុស្សយកទៅសំលាប់ចោលអ្នកខ្លះទៅក៏បានរត់រួចខ្លះចឹងទោក៏ថាមិនបានចឹងរត់រួចកាលនឹងវាពិបាកណាស់ណា។
ខ្ញុំបានសោកស្តាយបងប្រុសមួយនាក់នឹងជាងគេព្រោះអីកាលនឹងគាត់បានរៀនចប់អស់ហើយកាលនៅជំនាន់មុននឹងគ្រាន់តែសញ្ញាប័ណ្ណរបស់គាត់នឹងមានដល់ទៅ៣ទៅ៤ឯនោះ
ហើយអាណិតគាត់ទៀតព្រោះអីកាលនឹងគាត់ស្លូត
ហើយបើឥឡូវនឹងបើគាត់មានអាយុនឹងអាយុរបស់គាត់នឹងប្រហែលជាបាន៦០ជាងហើយ។

កៈ ចុះអ៊ុំមានបានដឹងដែរឬទេថាគាត់បានរៀនខាងផ្នែកណាដែរ?

ខៈ
គាត់បានរៀនច្រើនណាស់និយាយទៅនឹងប៉ុន្តែកាលនឹងម្តាយឪខ្ញុំនឹងគាត់ក៏មិនមានដែលនឹងគាត់ជាអ្នកក្រទេប៉ុន្តែគាត់បានតស៊ូអោយកូនៗទាំងអស់នឹងបានរៀនសូត្រតៗគ្នាប៉ុន្មានកាលនឹងមានតែបងប្រុសរបស់ខ្ញុំមួយនឹងទេដែលគាត់បានតស៊ូរៀនរហូតបានដល់ចប់តែម្តងកាលនៅជំនាន់នោះនឹងដូចថាកាលនឹងគាត់បានរៀនឡើងអស់ថ្នាក់ហ៉ា។

កៈ
ចាស!ហើយនឹងកាលពីជំនាន់ពពតនឹងក្រុមគ្រួសាររបស់អ៊ុំកាលសម័យនឹងគេបានជំលៀសទៅណាដែរ?

ខ៖
ខ្ញុំកាលដែលពីជំនាន់ឆ្នាំ១៩៧០មកនឹងខ្ញុំបានទៅនៅក្នុងស្រុកឪពុករបស់ខ្ញុំដែលស្រុករបស់ឪពុកខ្ញុំនឹងកាលនឹងនោះស្រុករបស់គាត់នឹងគឺនៅស្រុកកំពុងចាម។

ក៖ ចាស!!

ខ៖
ហើយដល់ពេលបានមកនៅទីនេះនឹងគេមិនបានជំលៀសយើងនោះទេព្រោះអីគេថាយើងនឹងជាអ្នកស្រុកមូលឋានចឹងហើយគេមិនបានធ្វើការជំលៀសយើងនឹងទេ
គេមិនអោយជំលៀសទៅណានោះទេកាលនឹងគេអោយយើងនៅតែក្នុងស្រុកនឹងរួចដល់រហូតមកនឹង។

ក៖ ចឹងចុះក្រុមគ្រួសាររបស់អ៊ំពេលនឹងមិនបានបែកគ្នាទេគឺនៅជាមួយនឹងគ្នា?

ខ៖
អត់មានបានបែកគ្នាទេកាលនឹងនោះបើមានបែកដែលគឺមានតែកូនចៅរបស់គាត់ដែលបានទៅធ្វើជាទាហានទេកាលនឹងនោះប្រមាណជាតែ៣ទៅ៤នាក់នឹងពេលនឹងគេបានទៅធ្វើជាទាហានអាពតនោះ
មិនមែនទៅធ្វើនឹងចិត្តឯឬស្ម័គ្រចិត្តចូលធ្វើជាទាហាននឹងនោះទេកាលនឹងនោះពេលដែលចូលទៅធ្វើជាទាហាននឹងពួកគេបានចាប់ចូលទេ។

ក៖ ហឺ!ចឹងគេមកបង្ខំយកទៅធ្វើ។

ខ៖ នឹងដូចជាវាមកបង្ខំយើងនឹងតែម៉ងអោយទៅចូលធ្វើជាទាហាននឹងនោះ
អត់បានថានិយាយអោយយើងនឹងទៅចូលដោយស្មាគចិត្តនោះទេ។

ក៖ ចាស!

ខ៖
ដូចថាពេលដែលមានផ្ទះណាដែលមានកូនប្រុសនឹងគេអោយយកទៅធ្វើជាទាហាននឹងចាប់ចូលទៅធ្វើទាំងអស់ហើយកាលនឹងខ្ញុំទៅនៅឯស្រុកឪពុករបស់ខ្ញុំនោះទេកាលនឹងនោះដែលថាបងនឹងប្អូនរបស់ខ្ញុំដែលគេបានចូលទៅនឹងណាហើយមានបងនឹងប្អូនរបស់ខ្ញុំមួយនឹងគេបានចូ

លទៅនៅក្នុងជំនាន់អីជំនាន់កាលនឹងគេអឺគេបានទំលាក់សម្តេចហ៎កាលនឹងមានបងមួយទៀតនឹង
បងខ្ញុំមួយទៀតនឹងបើនិយាយទៅកាលនឹងគាត់កើតនៅក្នុងឆ្នាំខាលត្រូវជាអាយុបងលោកហ៊ុនសែនយើងនឹងទៀតព្រោះអីលោកហ៊ុន
សែននឹងគាត់បានកើតនៅក្នុងឆ្នាំរោងចំណែកឯបងប្រុសរបស់ខ្ញុំនឹងគាត់បានកើតនៅក្នុងឆ្នាំខាលនឹងណា អានឹងគាត់បានចូលទៅធ្វើការបំរើនឹងតាំងពីកាលជំនាន់ឆ្នាំ១៩៧០
ដែលពេលនឹងគាត់បានចូលទៅក្នុងទាហានរំដោះនឹងកាលនឹងគាត់បានចូលធ្វើជាទាហានរំដោះអីគេនឹងសំរាប់បងប្រុសមួយនឹង
ហើយបងប្រុស១នាក់នឹងក៏បានបាត់ដំណឹងសូត្រឈឹងគ្មានដែលបានឃើញអីនោះទេវាចឹងមានន័យថាគាត់បានបាត់ហើយស្លាប់បាត់អស់ទៅហើយគ្មានបាននឹងនៅរស់ទៀតនោះទេហ៎ី។

ក៖ ចាស!ចឹងសោកស្តាយមែនទែន។

ខ៖ នឹងហើយហ៎ី

ក៖
ហើយកាលនឹងសំរាប់អ៊ុំវិញកាលនឹងគេបានប្រើអ៊ុំអោយធ្វើអ្វីខ្លះនៅក្នុងសម័យជំនាន់អាពត?

ខ៖
អូ្វកាលនៅជំនាន់របស់ខ្ញុំនេះនឹងនេះកាលដែលខ្ញុំបាននៅក្នុងសម័យកុមារតូចៗនឹងហេសនេះ
ពេលនោះខ្ញុំនឹងគេបានប្រើទៅកាប់ដីកាប់អីមករហូតមកនឹងពេលនោះនឹងហើយពេលនឹងខ្ញុំបាននឹងលើកចបមិននឹងរួចផងនឹងកាលនៅក្នុងសម័យជំនាន់អាពតនឹងនោះហហាហ។

ក៖ កាប់ដីនៅក្នុងម្តុំនឹងដែរឬ?

ខ៖
កាប់វាចេះតែដើរទៅនេះទៅនោះចឹងទៅកាលនឹងវាមិនបាននឹងភ្ជួរនោះទេវាចេះតែប្រើយើងនឹងអោយដើរទៅកាប់ទៅតាមនឹងទៅ
វាចេះតែប្រើអោយតែមានការងារធ្វើចឹងទៅកាលនឹងនោះ។

កៈ ចុះអ៊ុំមានបានចាំថាវានៅកន្លែងណាដែរឬទេនៅឯណាដែរអ៊ុំ?

ខៈ ចាស?

កៈ តើអ៊ុំបានជីកកាប់ដីនឹងប៉ុន្មានកន្លែងដែរហើយពេលនៅដល់ពេលបច្ចុប្បន្នយើងនឹង?

ខៈ
កាលនឹងបានកាប់ដីចំការនឹងបានទៅកាប់នៅគ្រប់កន្លែងនឹងកាលនឹងមិនមានផ្ទះឡើងស្អេកស្កាសចឹងពេកទេកាលនឹងមានផ្ទះគេនៅនឹងមានតែមួយៗនោះទេ។

កៈ កាលនឹងអ៊ុំកាប់ដីនឹងសំរាប់នឹងធ្វើអ្វីដែរ?

ខៈ
វាសំរាប់ទុកដាំបន្លែដាំបន្លុកចឹងទៅកាលនឹងនោះវាចេះតែប្រើយើងនឹងទៅអោយតែមានការងារធ្វើចឹងទៅកាលនឹងវាប្រើអោយទៅដាក់ដាំពោត
ដាក់ដាំដើមល្ពៅអីៗនឹងគ្រាប់បែបគ្រាប់យ៉ាងចឹង
ហើយតែពេលដែលវាអោយយើងនឹងដាក់ដាំចឹងទៅវាក៏មានសំរាប់ទៅជញ្ជូនទៅនេះទៅនោះចឹងទៅយើងនឹងក៏វាមិនសូវបានទ្រាំនៅតែក្នុងនឹងដែលព្រោះអីវាបញ្ជូនយើងនឹងម្តងទៅធ្វើនៅនេះម្តងទៅធ្វើការងារនៅឯនោះចឹងទៅ។

កៈ អូកាលពិតទៅកាលសម័យកាលនោះវាលំបាកចឹងណាស់អ៊ុំ។

ខៈ ហ្វស
តែក្មេងសម័យឥឡូវពេលដែលនិយាយទៅនឹងវាមិនបានទៅជឿនោះទេវាមិនបានទៅជឿថាកាលនៅសម័យពពតនោះនឹងវាឆ្លងកាត់ការលំបាកយ៉ាងម៉េចខ្លះនោះទេ
បើថាពេលដែលយើងនឹងនៅស្រុកយើងផងនឹងវាឡើងលំបាកប៉ុណ្ណឹងហើយនៅទំរាំតែគេខ្លះបានគេយកទៅជំលៀសអោយទៅធ្វើការងារនៅ
ឯស្រុកគេនោះនឹងវារឹតតែលំបាកវេទនាទៀតនោះ។

គៈ
កាលជំនាន់នឹងវាមិនទៅលំបាកចិត្តអីកាលនឹងនោះតែជំនាន់នឹងវាលំបាកចិត្តព្រោះអីគិតច្រើនពេកថានឹងទៅរកស៊ីស្អីនឹង។

ខ៖ អើកាលជំនាន់របស់ឯងនឹងវាមិនទៅលំបាកអីហើយពេលជំនាន់អញកើតនឹងវាលំបាកតែឯងនឹងវាមិនលំបាកបើ
ឯងវាមិនធ្លាប់បានឆ្លងកាត់និយាយទៅនឹងឯងក៏មិនបានដឹងដែរនឹងផងហីសៗ

គ៖
នៅសម័យជំនាន់អាពតនឹងវាមិនទៅលំបាកអីកាលនឹងនោះគេអោយយើងនឹងស៊ីស្រាបអីស្រាប់នឹងកាលនឹងនោះ។

ខ៖ ហីសៗៗ

ក៖ ហើយកាលនឹងអ៊ុំបានធ្វើការងារនឹងគេបានអោយអ៊ុំទៅធ្វើការងារនឹងចាប់ផ្ដើមមកពីម៉ោង

ប៉ុន្មានដល់ម៉ោងប៉ុន្មានដែរកាលនឹងនោះ?

ខ៖
កាលនឹងបើនិយាយទៅនឹងខ្ញុំបានធ្វើការងារនឹងគេអោយខ្ញុំនឹងទៅធ្វើការងារពីព្រលឹមឡើងនឹងគេអោយយើងក្រោកឡើងនឹងទៅកើបអាចម៍គោ
ហើយបើថាកាលនៅពេលព្រលឹមឡើងនឹងបើសិនជាយើងមិនបានកើបអាចម៍គោបានទេវាមិនអោយយើងបានហូបអីនោះទេកាលនឹងនោះលុះត្រាតែយើងនឹងបានដើររើសទៅរើសអាចម៍គោនឹងអោយត្រូវតាមចំនួនរបស់គេដែលគេបានដាក់អោយយើងធ្វើចឹងណា
ហើយពេលដែលបានទៅរើសអាចម៍គោនឹងមកនឹងកាលនឹងខ្ញុំមិនចេះតែថានោះទេ
ខ្ញុំនឹងកាលនឹងមិនសូវជាបានដេកប៉ុន្មាននោះទេពេលដែលដេកនឹងនឹកឃើញតែពីរឿងគោនឹងវាជុះអាចម៍ព្រោះកាលនឹងខ្លាចតែរើសអាចម៍គោនឹងវាមិនបានពេញទីដូចជាគេ
គេនឹងយកយើងទៅសំលាប់ចោលកាលនឹងនោះវាចឹងឯងហាៗ
ហើយមួយវិញទៀតនឹងបើថាយើងនឹងរើសមិនបានគ្រាប់ទេហើយនឹងរើសមិនត្រូវតាមគេអោយយើងរើសគ្រាប់ចំនួននោះទេនឹងយើងនឹងមិនបានហូបអីទេគេមិនទៅអោយយើងទេកាលនឹងពេលដែលនៅក្មេងៗនឹងម្លោះហើយចេះតែនេះចឹងទៅ
ហើយម្លោះហើយនឹងកាលនឹងផ្ទះរបស់ខ្ញុំនឹងគឺបានទៅនៅខាងត្បូងឯនោះកាលនឹងទៅនៅជិតនឹងរោងអាមច៍គោហើយចឹងពេលជួនកាលចឹងទៅខ្ញុំនឹងវាដេករាងជ្រួលចឹងទៅអត់បានអាចម៍គោទេចឹងទៅហីសៗហើយពេលជួនកាលទៅបានប្រុងប្រយ័ត្នចឹងទៅក៏បានទៅកើបអាចម៍

គោនឹងយកទៅដើម្បីនឹងថ្លឹងចឹងទៅ ចឹងបានថាកាលនឹងអាចម៍គោដែលរើសបានមកនឹងត្រូវបានគេយកទៅថ្លឹងទៀតណាអាចម៍គោនឹងណាហាហាហា

ក៖ ហឺសៗ

ខ៖ ហាហាហា

គ៖ កាលនឹងបើថាយើងនឹងបានរើសមិនគ្រាប់គេអោយយើងនឹងរើសគេនឹងយកយើងនឹងទៅវៃចោល។

ក៖ ហើយទៅកាលនឹងគេបានអោយរបបអាហាររបស់អ៊ុំបានប៉ុន្មានពេលដែល?

ខ៖ នោះហើយកាលនឹងទាល់តែនេះចឹងទៅបានជាគេបានអោយរបបចឹងទៅហើយថាបើអត់បានរើសពេញគេអោយយើងនឹងទៅរើសនឹងទេគេមិនទៅអោយយើងបានហូបទេ ហើយបើថាយើងនឹងអត់បានអាចម៍គោចំនួន២០គីឡូងឡើងចឹងទៅអត់បានបាយហូបទេកាលនឹងនោះហាហាហា។

ក៖ ហាហាហើយកាលនឹងអ៊ុំអាចនឹងរកបានអាចម៍គោគ្រាប់ចំនួនទេអ៊ុំ?

ខ៖ ចាស?

ក៖ កាលនឹងអ៊ុំចេញទៅរកអាចម៍គោនឹងដឹងតែបានហើយ?

ខ៖ នឹងហើយ

ក៖ អត់ដែរនឹងថាអត់បានអាចម៍គោហើយគេមិនបាននឹងអោយបបរដល់អ៊ុំទេ?

ខ៖ អត់ទេបើនេះដែលថាអត់ម៉េចបើកាលនឹងម្នាក់ៗនឹងគេបានប្រុងប្រយត្ន័រាងៗខ្លួនៗនឹងហើយណាមួយកាលនឹងនោះវាសំបូរសត្វគោនឹងណាស់កាលនឹងវាសំបូរគោ គោវាសំបូរ។

កុំទៅវាអាចម៍គោនឹងវានៅឯណាក៏ដោយអោយតែថាឃើញនឹងខំប្រឹងប្រមូលវាមកសំរាប់យកមកទុកអោយគេហើយទោះបីត្រូវបានយកដៃនឹងទៅកើបក៏ដោយកាលនឹងអោយតែថាបានយកអាចម៍គោនឹងយកទៅថ្លឹងហាហាហាហឺស។

ក៖ ចាស!ចឹងសំរាប់នឹងដូរបបរសំរាប់ហូប ហើយកាលនឹងគេបានអោយបបរដល់អ៊ុំស្រីបានប៉ុន្មានពេលដែលកាលនឹងអ៊ុំ?

ខ៖ ហឺស!កាលនឹងបានបបរនឹងបានតែ៣វែកហើយ១ចាន ចានគេនឹងកាលនឹងតូចៗប៉ុនៗនេះនឹងឯងហើយកាលនឹងបបរនឹងវាមិនមែនដូចពេលនេះឯណាវាឡើងរាវក្រខ្លួកនឹងកាលនឹងមានតែទឹកសំរាប់អោយយើងហូប ហាហាហាមានអីទេ។

ក៖ តែចឹងកាលនឹងគេបានអោយអ៊ុំបានប៉ុន្មានពេលដែល?

ខ៖ បើសិនជានេះចឹងគេបានអោយបបរយើងនឹងបាន៣ពេលចឹងដែលដូចថាបើសិនជាយើងបានទៅរកអាចម៍គោនឹងបានហើយបើថាបើយើងទៅរកអាចម៍គោនឹងមិនបានវិញនឹងគេបានអោយយើងតែ២ពេលទេគឺពេលល្ងាចនឹងពេលថ្ងៃអត់ពេលព្រឹកប្រលឹមចឹងទៅចឹងណាបើថាពេលប្រលឹមឡើងនឹងយើងទៅរកអាចម៍គោនឹងវាមិនបានទេកាលនឹងគេមិនបានទៅអោយបបរយើងពេលព្រលឹមឡើងនោះទេ។

ក៖ ចាស!

ខ៖ ហាហាហា

ក៖ ចឹងមានតែការងារប៉ុណ្ណឹងនោះទេដែលអ៊ុំបានទៅធ្វើការងារជាអ្នកដែលកាប់គាស់ដី?

ខ៖ នឹងហើយកាលនឹងមានទេប៉ុណ្ណឹងនោះទេកាលនឹងនោះ។

ក៖ ចាស!ចឹងកាលនឹងអ៊ុំបានទៅដើររើសអាចម៍គោនឹងគាប់ដី។

ខ៖ ចាស!នឹងហើយ

ក៖ ចឹងកាលនៅជំនាន់នឹងអ៊ុំគិតថាទិដ្ឋភាពមួយណាដែលធ្វើអោយអ៊ុំបានចង់នឹងចាំជាងគេ?

ខ៖
ទិដ្ឋភាពដែលធ្វើអោយអ៊ុំបានចងនឹងចាំជាងគេនឹងគឺអាពេលដែលអ៊ុំបានទៅលើចបកាប់មកវាមិនរួចនេះព្រោះអីកាលនឹងវានៅក្មេងតូចៗចឹងហើយកាលនឹងវាមិនទៅមានកំលាំងអីច្រើនវាមិនបាននឹងពេញកំលាំងទៅធ្វើការងារអីនឹងហើយដឹងចឹងហើយនឹងពួកវានឹងនៅតែអោយយើងនឹងទៅកាប់ដីទៀតហើយទៅកាលនឹងអាហូបចុកនឹងក៏វាមិនគ្រាប់គ្រាន់..

ក៖ ចាស!

ខ៖ ហើយវាបានប្រមូលអោយយើងនឹងបានចូលទៅ
ហើយកាលនឹងមើលកាលនឹងវាបានប្រមូលយើងនឹងអោយចូលទៅ
អោយយើងនឹងអាយុមើលទឹមបានតែ១២ទៅ១៣ឆ្នាំនឹងវាបានអោយយើងនឹងទៅចូលនៅកងចល័តយើងនេះហើយកាលនឹងបើគេធំៗចឹងទៅកាលនឹងវាមិនទៅនេះអីតែពេលនឹងកាលនឹងយើងនឹងវានៅវាងតូចៗដែលនឹងចឹងហើយកាលនឹងធ្វើការងារមួយនឹងវាមិនបានទៅស្រួលអីដូចជាគេបានធ្វើព្រោះអីគេធំៗហើយគេបានលុតដំទៅ។
ក្មេងខ្លះចឹងទៅគេបានទៅសន្សំពោតអីព្រោះអីកាលនឹងក្មេងៗនឹងគេបានអោយយើងនឹងទៅសន្សំពោតនឹងយកមកលីងហូបអីចឹងកាលនឹងដើម្បីនឹងយកមកហូបបានក្រៅចឹងទៅ។

ក៖ ចឹងកាលនឹងគេអោយយើងមានសិទ្ធិដើម្បីនឹងធ្វើម្ហូបខ្លួនឯងដែរឬទេ?

ខ៖ អត់ទេៗ

ក៖ ចុះការដែលអ៊ុំបានកាច់ពោតដើម្បីទុកមកសំរាប់ពិសារនោះ?

ខ៖
អូ!ដូចថាកាលនឹងពេលដែលគេអោយយើទៅកាត់ពោតនឹងយើងបានលួចលាក់ខ្លះដើម្បីនឹងយកមកទេកាលនឹងមិនមែននេះទេដូចថាកាលនឹងមិនមែនគេបានអោយយើងនោះទេយើងនឹងលួចលាក់ពីកងគេទេព្រោះអីពេលនឹងដូចថាពេលដែលយើងនឹងបានទៅកាត់ពោតនឹងយើងក៏បានកាត់ពោតហើយមានកាត់លួចលាក់ទុកទៀតយកមកទុក
ហើយពេលដែលដើរមកនឹងតាមផ្លូវនឹងយើងក៏ត្រូវតែលាក់លួចគេដែលមិនអោយគេមើលឃើញនោះទេ។

ក៖ ចុះកាលនឹងអុំមានដែលលួចគេដើម្បីនឹងបំពេញក្រពះគេដែលឬទេកាលនឹងនោះ?

ខ៖
ធីមិនដែលកាលនឹងនោះនិយាយថាមិនដែលយ៉ាងម៉េចហើយដូចថាពេលនឹងកាលនឹងអុំបាន
ទៅគាស់ដំឡូងគេចឹងទៅដូចជាមានដើមដំឡូងជ្វាចឹងទៅហើយក៏បានដកលួចមកលួចលាក់
ដាក់នៅក្នុងខោប៉ាវយើងមកលួចលាក់
ពេលខ្លះនឹងទៅយកដំឡូវនឹងទៅកប់នៅក្នុងដីចឹងទៅហើយពេលដែលស្រួលមើលទៅវាងស្ងា
តទៅក៏ទៅកកាយយកមកវិញចឹងមកហាហាហា។

ក៖ ដោយសារតែអំណាចនៃកាលឃ្លានពេក។

ខ៖ នឹងហើយហាហាហា

ក៖ ហឺស!ពិកបាកណាស់ហើយចឹងកាលនឹងគេមានបានទាន់អុំដែរឬទេកាលនឹង?

ខ៖ វាកាលនឹងអត់មានគេទាន់យើងធ្វើខុសដែរកាលនឹងហាហាហា។

គ៖
និយាយនឹងស្មានតែយាយឯងនឹងមិនបានកើតនៅក្នុងជំនាន់អាពតចឹងកាលនឹងយាយឯងនឹង
កើតទាន់ជំនាន់អាពតដែលកាលនឹង?

ខ៖ យី!អានីស!

គ៖ និយាយនឹងដូចជាបានដឹង។

ក៖ ហើយចឹងកាលនៅក្នុងសម័យនឹងគេមានបានភ្លាប់បានធ្វើបាបអុំអីដែរឬទេអុំ?

ខ៖
កាលជំនាន់អាពតនឹងគេមិនដែលធ្វើបាបអីអុំនោះទេកាលនឹងប៉ុន្តែកាលនឹងគេដូចថាគេបាន
ប្រជុំការប្រជុំអង្គភាពនឹងដូចថាវាឡើងដូចជារៀងរាល់ថ្ងៃទៅហើយការប្រជុំអីគេនឹង
គេធ្វើការពង្រឹងគោលជំហររបស់យើងនឹងរាល់តែថ្ងៃនឹងគេមិនដែលនឹងខានពេលណាមួយ
នោះទេ។

កៈ ហឺ !

ខៈ ហាហា

កៈ ហើយកាលនឹងគេប្រជុំពេលណាដែរ? ពេលព្រឹកឡើងឬក៏ពេលថ្ងៃ?

ខៈ ចាស?

កៈ គេបានយកអ៊ុំនឹងទៅធ្វើការប្រជុំនឹងនៅឯណាដែរ?

ខៈ
កាលនឹងគេបានយកទៅប្រជុំនឹងដូចថាមេគេចឹងគេមានមួយកងៗចឹងទៅគេក៏បានអោយទៅប្រជុំក្នុង១ក្រុមៗចឹងទៅកាលនឹងនោះ
គេបានធ្វើការណែលនាំយើងនឹងចឹងទៅថាអ្នកណាគេស្អប់អ្នកណាស្រលាញ់អ្នកណាគេអោយយើងនឹងធ្វើការនិយាយឡើងហើយធ្វើការទិទានគេចឹងទៅ។
ដូចថានរណាគេបានធ្វើខុសចឹងទៅគេក៏អោយយើងនឹងបានទិកទានយើងទៅថានរណាគេធ្វើខុសអីចឹងហើយគេបានអោយកែលប្រែវិញចឹងទៅគេបានធ្វើចឹងឯហើយពេលដែលគេប្រាប់យើងនឹងថាពេលក្រោយនឹងកុំអោយធ្វើចឹងអីចឹងទៅកាលនឹងនោះ។

កៈ
ចាស!ហើយកាលជំនាន់នឹងតើអ៊ុំមានបានភ្លាប់មើលឃើញអាពតបានយកមនុស្សទៅវៃចោលដែលឬទេអ៊ុំ?

ខៈ អត់ទេអត់ដែលបានឃើញទេ
កាលនឹងនៅក្នុងស្រុកនេះនឹងគេមិនទាន់បានអោយយកមនុស្សនឹងយកទៅវៃចោលនោះទេកាលនឹងមិនទាន់មាននោះទេ គ្រាន់តែកាលនឹងគេបានត្រៀមធ្វើជាទូ
កប៉ាល់អីកាលនឹងបានរួចអស់ទៅហើយ
កាលនឹងគេបានធ្វើកប៉ាលសំរាប់យកដាក់មនុស្សយកទៅវៃចោលនឹងណាប៉ុន្តែកាលនឹងវាវៃវាមិនទាន់។

កៈ អូ!

ខ៖
អានិងគេបានកងទៅអស់ទៅហើយកាលនឹងអាពេលនេះនឹងនោះអាពេលដែលគេនឹងប្រុងនឹងសំលាប់ហើយនឹងនោះតែកាលនឹងមានបុណ្យបានជួយដែលនឹងកាលនឹងគេបានយកទៅឯនេះណា៎ នៅឯដំរីស្រុតឯនោះគេបានអោយយើងនឹងបានទៅទាំងអស់
ហើយពេលនឹងគេបានអោយយើងនឹងបានទៅមើលកុនគេ
ហើយពេលនឹងកុនគេនឹងគ្មានបាននិយាយអីទេកុននឹងកុនគ គេបានហៅថាជាកុនគ កុនគនឹងហើយរួចដល់ពេលចឹងទៅដល់ពេលដែលវា..ហើយពេលនឹងគេបានរីករន្ធដៅហើយគេបានអោយយើងនឹងទៅធ្វើការអង្គុយនៅជុំវិញរន្ធដៅហើយប្រជាជននឹងបានទៅអង្គុយនៅជុំវិញរន្ធដៅនឹង
ហើយកាលនឹងគេសំលាប់ហើយកាលនឹងកន្លែងនឹងនៅខាងក្រោយព្រៃកល្ងួងយើងនេះ១រន្ធដៅនឹងទៅទាំងអស់គ្នា
គេមិនទៅមាននរណានៅនោះទេកាលធ្វើរន្ធដៅនឹងសំរាប់យកមនុស្សទៅសំលាប់ទាំងអស់គ្នានឹង
ហើយខ្ញុំកាលនឹងឪពុកម្ដាយខ្ញុំនឹងគាត់ទាំង២នាក់បានឈឺហើយម្ដាយខ្ញុំនឹងគាត់ជាអ្នកនៅមើល
ហើយមានបងស្រីរបស់ខ្ញុំនឹងគាត់ក៏ឈឺដែលដ៏ពេលចឹងទៅកាលនឹងគាត់បានថាអឺចឹងទៅអញមិនទៅនោះទេអាណាគេមកសំលាប់អញនៅដល់ផ្ទះក៏សំលាប់ទៅអញមិនទៅខ្វល់នោះទេអញមិនទៅទេ ចឹងហើយកាលនឹងគាត់មិនបានទៅទេ
ហើយស្រាប់តែពេលនឹងគ្រាន់តែវាបានបើសំដែងអាកុនគវានឹងយើងបានមើលបានតែប្រហែលមិនបានអួនឯងមកអង្គុយនឹងផងស្រាប់តែមានខ្យល់ព្យុះបក់មក
គឺថាពេលនឹងមានខ្យល់ពុះហើយមានភ្លៀងធ្លាក់មករកតែនឹងធ្វើស្អីនឹងមិនទៅកើតនោះទ។

ក៖ ចាស!ចឹងមិនបានមើលទេកាលនឹង?

ខ៖ នឹងហើយមានទៅបានមើលអីបើចឹង
ហើយកាលនឹងពេលដែលមានរឿងចឹងកើតឡើងនឹងក៏បានបែកខ្ញែកគ្នាចឹងទៅ។

ក៖ ចឹងកាលនឹងអ៊ុំក៏បានចូលរួចមើលទិដ្ឋភាពនឹងជាមួយដែរ?

ខ៖
នឹងហើយទៅកាលនឹងមានបងនឹងប្អូនខ្ញុំនឹងបានទៅមើលដែលកាលនឹងបានមើលទាំងអស់ទៅទាំងអស់គ្នា២ទៅ៣នាក់ តែកាលនឹងថាដូចជា៣នាក់បងនឹងប្អូនខ្ញុំនឹងនោះ ហើយកាលនឹងទៅជាមួយនឹងបងប្រុសរបស់ខ្ញុំនឹងដែលឥឡូវនឹងគាត់ទោមានប្រពន្ធនៅឯនេះឯណោះហើយចឹងកាលនឹងមានតែខ្ញុំនឹងបងប្រុសរបស់ខ្ញុំនឹង អស់ពីនឹងដូចខ្ញុំបានថាចឹងថាទៅអានេះនឹងមិនដឹងថានឹងទៅឯណាទៅឯណានោះទេ ព្រោះអីគ្មានបានដើរមកផ្ទះមកសំបែងអីទេកាលនឹងព្រោះអីស្រុកនឹងវានៅវាងឆ្ងាយ។

ក៖ ហឺ!កាលនឹងលំបាកមែនទែនហើយមានការបែកបាត់បងនឹងប្អូនទៀត។

ខ៖ ហឺ!

ក៖ ចាស!ហើយអ៊ុំ...

ខ៖ និយាយទៅនឹងវាកំសត់អត់ឃ្លាននឹងដែលនឹងមិនជាបានធម្មតានោះទេវាកំសត់។

ក៖ ចឹងអ៊ុំកាលនឹងណោះអ៊ុំមានបានធ្លាប់ឈឺដែរឬទេកាលនឹង?

ខ៖ តែកាលនៅជំនាន់នឹងនោះវាមិនដែលបានឈឺអីដែរវាមិនធ្លាប់ឈឺហាហាហា

ក៖ ចាស!

ខ៖ អត់ដែលបានឈឺហាហា

ក៖ ហឺកាលនឹងអ៊ុំនៅមានសុខភាពនៅម៉ាំហើយបានធ្វើការងារអោយគេរហូត។

ខ៖ នឹងហើយ

ក៖ ហឺ!

ខ៖
កាលនឹងជំនាន់នឹងអ្នកណាគេក៏ដូចជានរណាដែលកាលនឹងវាមិនសូវជាបានឈឺដូចថាកាលនៅជំនាន់នោះនឹងវាមិនសូវជាមានជាតិគីមីហើសៗៗ

ក៖ ចាស!!

ខ៖
ក៏ប៉ុន្មាននៅស្រុកនឹងណាអូនអើយបើនិយាយទៅនឹងវាវាងសំណាងចេះដែលនឹងដូចថាវាដូចថាវាបានអត់ឃ្លានមែនប៉ុន្តែយើងបាននឹងលួចអីស្អីបានហូបចឹងណាព្រោះអីកាលនឹងវាសំបូរដូចថាកាលនឹងវាបានសំបូរដូចជាពោត
សំបូរទៅដោយដំឡូងអីចឹងចុះទៅហើយយើងអាចលួចបានហើយយើងអាចហួបបានដូចមានដើមចេកនៅផ្ទះសំបែងអីរបស់យើងនឹងយើងអាចលួចហូបបានដូចជាពេលនឹងដើមចេកនៅផ្ទះរបស់ខ្ញុំនឹងអូដូចថាវាមានសាច់នឹងមិនចង់នឹងទាន់ផងកាត់យកមកដាក់ដាំហើយស្ងោរហូបហើយ
ហើយពេលនឹងណាមួយយើងមានដាំដើមចំពូអីនឹងចឹងនៅផ្ទះរបស់យើងនឹងហើយមានបានដាំនទោងដាំនទោងចឹងទៅយកទៅដាក់ដាំនៅក្នុងឆ្នាំសំរាប់នឹងធ្វើការដាក់ដាំទាំងឆ្នាំៗចឹងទៅសំរាប់នឹងស៊ីចឹងទៅជំនួសទៅអោយការហូបបាយ។
ហើយនិយាយទៅព្រោះដោយសារតែកាលនឹងដូចថាមានមេកងអីនឹងគេមិនសូវជាបានមើលឃើញចឹងណាដូចថាវាមើលឃើញដែលពេលខ្លះទៅនឹងប៉ុន្មានវាចេះតែរាងថ្មិចភ្នែកអីចឹងដែលណាមិនបានដូចស្រុកគេខ្លះនឹងបានឃើញតែភ្លើងអីនឹងវាមិនបានទេ
តែនៅនេះនឹងវាមិនអីនោះទេដូចថាយើងដាំអីសំរាប់ហូបអីចឹងវាបានមកសួរយើងដែលថាយើងនឹងកំពុងតែធ្វើអីគេអ៊ុំ?
ហើយយើងនឹងក៏បានឆ្លើយវិញថាយើងកំពុងតែដាក់ដាំទឹកអីសំរាប់ហូបដែលនឹងណាប្រាប់គេតាមចឹងទៅវាក៏ទៅវិញហើយ វាអត់សូវខ្លាំងដូចថាវាអត់នេះទេ
តែបើថាមានគេនឹងបានលួចរបស់អីធំដុំអីអានឹងខ្ញុំមិនបានដឹងទេ។
ខ្ញុំនឹងជូនកាលនឹងគេបានអោយខ្ញុំនឹងទៅជញ្ជូនព្រោះអីគេបានទៅដឹងពោតមកពីណានោះទេកាលនឹងនោះដូចជាមានអាពោតយើងរាងគ្រាប់ឡើងពណ៍ក្រហមនោះគ្រាប់ពោនឹងនោះហើយពេលនឹងគេបានអោយយើងនឹងទៅធ្វើការជញ្ជូនពេលដែលគេបានដឹងយកមកអោយហើយជូនកាលទៅនឹងយើងលួចទៅដាក់នៅកន្លែងណាកន្លែងនៃអីចឹងទៅកាលនឹងហើយបានពេលហើយៗនឹងយើងក៏បានទៅយកមក
ហើយយកមកនឹងសំរាប់យកមកដើម្បីនឹងស្ងោរហូបចឹងទៅ។

ក៖
ចាស!ហើយពេលដែលបានដាច់អាពតមកនឹងដូចជាអ៊ុំមានមុខរបបអីគេដើម្បីចិញ្ចឹមជីវិតតាំងពីពេលដែលបានដាច់អាពតនឹងមក?

ខ៖ តាំងពីពេលដែលបានដាក់អាពតនឹងមកនឹងឪពុករបស់ខ្ញុំនឹងគាត់ថាដូចជាគាត់បានទៅអីខ្ញុំអីនឹងពេលដែលបានដាច់អាពតហើយនឹងខ្ញុំបានដឹងថាពេលដែលបែកហើយនឹងគេបានអោយយើងនឹងទៅយកស្អីៗនៅឯភ្នំពេញ
ដ៏ពេលកាលនឹងខ្ញុំក៏ទៅហើយកាលនឹងពេលដែលខ្ញុំបានទៅនឹងខ្ញុំក៏បានទៅយកអាអំបោះគេនឹង
អាអំបោះគេដែលគេយកមកធ្វើជាក្រមានោះគេយកធ្វើនឹងណាអំបោះនឹងមាន១គីបៗគេនឹងឡើងធំៗហើយក្នុង១គីបៗគេនឹងមានយ៉ាងហោចណាជាង១០០គីឡូចឹងហើយកាលនឹងខ្ញុំបានទៅយកមកនឹងបានចំនួន៣គីប
ខ្ញុំបាន៣គីបខ្ញុំក៏បានយកមកដូរខ្ញុំក៏យកទោដូរស្រូវអីបានហើយទៅចំណែកឯលោកឪពុករបស់ខ្ញុំនឹងគាត់ក៏យកទៅបាន៥ដែលគាត់បានធ្វើជាអួនដែលគេសំរាប់យកទៅបង់ត្រីនឹងណាយកទៅកាលនឹងគាត់នឹងក៏បានយកទៅធ្វើអួននឹងសំរាប់នឹងអូស
ចំណែកឯខ្ញុំកាលនឹងពេលដែលឪពុករបស់ខ្ញុំនឹងគាត់បានត្រីពីការដាក់អួនសំរាប់នឹងនេសាទចឹងទៅក៏ធ្វើជាត្រីបន្លាក់ទុកហើយបានយកត្រីនឹងយកទៅដូរនៅផ្សារព្រៃកលៀបនឹងកាលនឹងប៉ុន្តែកាលនឹងយើងបានយកទៅដូរនៅឯផ្សារហើយក៏បានចេះតែបានហូបជាបន្តបន្ទាប់មករហូតមក។

ក៖ ចាស!!

ខ៖ ហើយខ្ញុំក៏បានចេះតែបានរកអីផងមកទៀតចឹងទៅ។

ក៖ ចាស!
ចាស!ចឹងពេលដែលបានដាច់មកនឹងអ៊ុំមិនបាននឹងមានមុខរបបអ្វីបន្ថែមផ្សេងទៀតទេណ៎អ៊ុំ?

ខ៖ ចាស!!

ក៖ ចឹងមានតែ១នឹងទេ
ចាសហើយចឹងកាលដែលអ៊ុំនៅពីក្មេងៗនឹងតើអ៊ុំធ្លាប់បានស្រមៃដោយធ្វើការគិតថាពេលដែលអ៊ុំធំឡើងអ៊ុំនឹងចង់ធ្វើអ្វីនោះទេអ៊ុំ?

ខ៖ អត់ដែលសោះហាហា អត់ដែលថានឹងចង់ធ្វើអ្វីនោះទេហាហា។

ក៖
ចាស!ហើយចឹងកាលដែលអ៊ុំនៅពីក្មេងៗនឹងចឹងតើអ៊ុំចូលចិត្តនឹងលេងល្បែងអីជាងគេដែលពេលដែលនៅកាលពីតូចៗនឹង?

គ៖ កាលនឹងគាត់មានទៅលេងអីកាលនឹងគាត់លេងតែល្បែងអីនឹង។

ខ៖ ហាហាកាលនឹងខ្ញុំមានទៅលេងអីកាលនឹងខ្ញុំមានតែធ្វើការលេងត្រែសនឹង។

ក៖ ចាស!ចឹងអ៊ុំចូលចិត្តលេងល្បែងត្រេសណ៎អ៊ុំ?

ខ៖ នឹងហើយ

ក៖ ចឹងល្បែងនឹងវាមានផ្លែងក្រឆ្មានឹងមែនអ៊ុំ?

ខ៖ នឹងហើយហឺស

ក៖ ហើយចុះចំណែកឯល្បែងប្រជាប្រិយខ្មែរយើងវិញ?

ខ៖ អូអានឹងខ្ញុំអត់ចេះសោះតែសម្បីតែរាំនឹងក៏ខ្ញុំអត់ចេះដែរអត់ចេះរាំដែរ។

គ៖ កាលមុននឹងបានចាក់ឆ្នោតបាន២០០។

ក៖ ចាស!!

ខ៖
ហើយកាលនឹងលឺតែគេចាក់បាសអីនឹងតែថាអោយខ្ញុំនឹងទៅរាំអីនឹងខ្ញុំមិនចេះរាំដូចគេអីចឹងទេហោសៗ។

ក៖ ហើយចុះចំណែកឯបទចំរៀងវិញតើអ៊ុំមានបានចូលចិត្តដែរឬទេ?

ខ៖ ខ្ញុំចូលចិត្តខ្ញុំចូលចិត្តស្តាប់តើបទចំរៀងអីនឹងដូចជាបទចំរៀងលោកតាស៊ុន ស៊ីសាមុតអីនឹងខ្ញុំចូលចិត្តស្តាប់តើតើចំណែកឯបទចំរៀងសម័យឥឡូវអីនឹងខ្ញុំមិនសូវជាចូលចិត្តស្តាប់នោះទេនិយាយតាមត្រង់ទៅ ហើយបើថាមានបទចំរៀងកាលនៅសម័យកាលពីដើមនឹងខ្ញុំបានស្តាប់ដល់ចប់ៗតែបទសម័យនឹងចឹងវាខ្ជិលណាស់។

ក៖ ចឹងកាលនៅក្នុងសម័យពីដើមមកនឹងតើបទណាមួយដែលអ៊ុំបានចង់ចាំរហូតមកដល់សព្វថ្ងៃនឹងដែលឬទេ?ហើយមានចំណងជើងថាយ៉ាងម៉េចដែរទៅអ៊ុំ?

ខ៖ ហឺសៗៗ

ក៖ ចឹងអ៊ុំចាំដែរឬទេដូចជាបទចំណងជើងបទចំរៀងដែលអ៊ុំចូលចិត្តណា?

ខ៖ បទចំណងជើងដូចជាលោកតាស៊ុនស៊ីសាមុតអីនឹងហេស៎?

ក៖ ចាស!!

ខ៖ ខ្ញុំវាមិនសូវជាបានចាំនោះទេប៉ុន្តែបើគេច្រៀងអីនឹងខ្ញុំអាចនឹងចាំបានតែបើថាអោយទៅចាំចំណងជើងរបស់បទចំរៀងនឹងនោះខ្ញុំចាំវាមិនបាននោះទេ ខ្ញុំវាមិនសូវាបានជាចង់ចាំនោះទេ។

ក៖ ហើយចឹងអ៊ុំមានបានចេះច្រៀងដែរឬទេ?

ខ៖ ខ្ញុំហឺសៗៗកាលពីមុននឹងមកខ្ញុំចេះច្រៀងខ្លះតែបើថាអោយរាំវិញនឹងអត់ចេះទេហាហា

ក៖ ចឹងអាចអោយអ៊ុំជួយច្រៀងតែបន្តិចមក។

ខ៖ អាសហាហាហាហា

ក៖ ហាហា

ខ៖
អត់ទេក្មួយអើយអ៊ុំច្រៀងទៅវាមិនរួចនោះទេកាលពីមុនៗមកនឹងចេះតែច្រៀងទៅជាមួយនឹងគេជាមួយឯងចឹងទៅតែដល់ពេលឥឡូវនឹងអ៊ុំវាទៅមិនរួចនោះទេហោសៗៗៗ។

ក៖ ចឹង!អ៊ុំលែងបានស្ដាប់សោះឡើយបទចំរៀងអីឥឡូវនឹង?

ខ៖ ចាស!!

ក៖
ហើយបន្ទាប់មកនឹងដូចថាអ៊ុំសាកស្រមៃមើលថាកាលពីមុននឹងអ៊ុំធ្លាប់មានបទពិសោធន៍អីគេដែលធ្វើអោយអ៊ុំចង់ចាំនៅក្នុងជីវិតរបស់អ៊ុំដែលធ្វើអោយអ៊ុំមិនអាចនឹងបំភ្លេចបានសោះឡើយ?

ខ៖
ទេបើថាអោយអ៊ុំនឹងមិនអាចនឹងធ្វើការបំភ្លេចបាននឹងសោះឡើយនឹងមានតែកាលនៅសម័យរដ្ឋកម្ពុជានឹងឯវាវេទនាចង់ជាងនេះទៅទៀតនឹងទាល់តែថាយើងនឹងពេលនឹងយើងនឹងវាអត់ស៊ីហើយគេបានទៅចាប់អោយធ្វើជាទាហានអីចឹងទៅចឹងហើយនឹងបានជាវាឡើងវេទនាចឹងហើយបានជាខ្ញុំនឹងវាឡើងខ្ជិលហើយខ្ញុំនឹងក៏វាបាននឹកថាកាលនឹងយើងវាក្រហើយដូចថាយើងវាបាននឹងឆ្អែកនឹងរបបមួយនឹងខ្លាំងថាពេលនឹងវាមានអាពតទៅអាពតតែមកដល់សម័យរដ្ឋកម្ពុជានឹងវាចង់ខ្លាំងជាងអាពតនឹងទៀតណាំ។

ក៖
ចឹងកាលនឹងវាយ៉ាងម៉េចខ្លះទៅចឹងដូចជាអ៊ុំបានជួបនៅបញ្ហាអ្វីគេដែលធ្វើអោយអ៊ុំតក់ជាប់នៅក្នុងអារម្មណ៍របស់អ៊ុំ?

ខ៖
ដូចថាយើងនឹងវាអត់ស៊ីអីផងចឹងហើយយើងនឹងវាអត់មានស៊ីអីផងចឹងវាវាងពិបាកចឹងវាលំបាកអត់មានផ្ទះអត់មានសំបែងគេបានចាប់ទៅធ្វើជាទាហានអីចឹងទៅណា។

ក៖ ចាស!ចឹងតែប៉ុណ្ណឹងទេអ៊ុំន៎?

ខ៖ នឹង!

ក៖ ហើយចុះសំរាប់ឯបទពិសោធន៏ល្អៗនៅក្នុងជីវិតរបស់អ៊ុំនឹងតើមានអ្វីគេខ្លះដែរ?

ខ៖
តែកាលនឹងខ្ញុំវាបានសំណាងដែលកាលនឹងព្រោះអីកាលនឹងនោះខ្ញុំបានចេះតែធ្វើការរើលបំរាស់ទៅកាលកូននៅពីតូចៗនឹងខ្ញុំក៏មិនស្រួលដែលកាលនឹងហួសហើយកាលនឹងបើខ្ញុំមិនាបានលក់ដីនឹងនោះខ្ញុំមានហើយខ្ញុំមិនបាច់នឹងធ្វើអីក៏បានដែរ
គ្រាន់តែដីរបស់ខ្ញុំនៅឯមាត់ទន្លេនេះណំវាមានតំលៃដល់ទៅ៣០ម៉ឺនដុល្លាឯនោះប៉ុន្តែខ្ញុំវាបានធ្វើការលក់វានិងមុនគេអោយនឹងកាលនឹងខ្ញុំលក់ដីនឹងបានលុយតែ៥០០ដុល្លាទេកាលនឹងនោះខ្ញុំប្រាប់ទៅព្រោះអីកាលនឹងនោះយើងនឹងវារាងអត់ហើយនឹងចឹងហើយយើងក៏ចេះតែនេះទៅចេះតែលក់ទៅកាលនឹងហើយដល់ពេលចឹងណាមកដល់ឥឡូវយើងនឹងពេលដែលបាននឹកឃើញរឿងនឹងឡើងមកម្តងៗនឹងវាស្តាយមិនធម្មតានោះទេណាហើយកាលនឹងណាពេលដែលដេកៗទៅនឹងនឹកឃើញ។

ក៖ ចាស!កាលវាលក់ទៅខុសលុយគ្នាច្រើនតែវាបានហួសបាត់ទៅហើយចឹងកាលនឹង។

ខ៖ នឹងហើយ

ក៖ ចឹងបានថាហាងឆេងដីវាមើលមិនទៅឃើញដែល។

ខ៖ នឹងហើយ

ក៖ ចាស!!

ខ៖ ហើយបើនិយាយទៅនឹងសំណាងរបស់យើងនឹងវាមិនដល់។

ក៖ ហើយចឹងអ៊ុំមានដីតែមួយកន្លែងនឹងទេ?

ខ៖ ដីរបស់ខ្ញុំនឹងមាន២ទៅ៣កន្លែងឯនោះប៉ុន្តែកាលនឹងខ្ញុំលក់ទៅនឹងវាចេះតែខុស។

ក៖ ចឹងឥឡូវនឹងអ៊ុំបានធ្វើការលក់អស់ហើយនៅសល់តែដីនៅផ្ទះនឹងមួយទេ?

ខ៖
នឹងហើយបើគិតទៅពេលដែលខ្ញុំបានលក់ដីនៅឯនោះនឹងវាបានលុយតែ១៦០០ដុល្លាទេហើ

យយកលុយនឹងដើម្បីនឹងយកមកផ្គួបធ្វើផ្ទះនេះឡើង ហើយសំរាប់យកទៅអោយកូនបានរៀនសូត្រអីចឹងផងហើយទៅមានកូន១ទៀតនឹងវាមានប្រពន្ធអីហើយចឹងវាគ្រាន់តែមានប្រពន្ធនឹងគេបង្គាប់ចំនួនលុយ២០០០ដុល្លាបាត់ទៅហើយចឹងហើយនឹងវានៅសល់បានប៉ុន្មានលក់ទៅនឹងសំរាប់តែអោយថ្លៃការវាអីនឹងដែរចឹងទៅ។

ក៖ ចាស!!

ខ៖ ហើយដំពេលដែលគេបានជំពាក់អីចឹងខ្លះទៅហើយក៏អោយគេទៅចឹងក៏បានអស់ចឹងទៅលុយនឹងវាមិនទៅនៅសល់អីហើយដំពេលចឹងទៅខ្ញុំក៏បានអោយកូនអីនឹងវាបានទៅក្រៅទៅធ្វើការងារនៅប្រទេសកូរ៉េអីចឹងទៅកាលនឹងហើយក៏វាបានធ្វើការងារនៅប្រទេសកូរ៉េនឹងបានផ្ញើរលុយអីអោយយើងខ្លះចឹងដែលទៅ វារាងធូទៅចឹងដែលជីវ:ភាពនឹងវាមិនទៅរកតឹងពេកទេ។

ក៖ ចឹងអ៊ុំមានកូនប្រុសនាក់ដែលគាត់ទៅធ្វើការងារនៅប្រទេសកូរ៉េនំអ៊ុំ?

ខ៖ចាស!!

ក៖ គាត់អីគាត់បានទៅធ្វើនឹងបានប៉ុន្មានឆ្នាំដែរ?

ខ៖ គាត់បានទៅអស់រយៈពេលប្រហែលជា៣ទៅ៤ពាន់ហើយ។

ក៖ ហើយចឹងគាត់មានគំរោងអីដើម្បីនឹងមកវិញដែលឬទេ?

ខ៖ ហឺស!ខ្ញុំមិនសូវជាដឹងទេរឿងវានឹងមិនដឹងថាវានឹងមកហើយធ្វើអ្វីៗនោះទេខ្ញុំនឹងវាមិនសូវជាបានដឹងរឿងរបស់វាដែលនឹងហេសៗ។

ក៖ ហើយចុះចំពោះអ៊ុំស្រីផ្ទាល់វិញតើអ៊ុំមានគំរោងអ្វីសំរាប់ថ្ងៃអនាគត់សំរាប់ក្រុមគ្រួសាររបស់អ៊ុំនឹងជីវិតរបស់អ៊ុំតទៅមុខទៀតដូចជាអ៊ុំចង់ធ្វើការផ្លាស់ប្តូរមុខរបរនឹងតើអ៊ុំចង់ធ្វើអ្វីដែលនឹងអាចផ្លាស់ប្តូជីវិតរបស់ខ្លួនឯង?

ខ៖
ហឺសសព្វថ្ងៃនឹងខ្ញុំមិនមានបានទៅសល់អីនោះទេតែមានបំណងមួយគឺចេះតែខំប្រឹងរកទៅក្រែងលោលមានលុយ២០០០ទៅ៣០០០ដុល្លាដើម្បីនឹងសំរាប់ទុកចោលពេលដែលខ្លួននឹងវាចាស់ទៅមានអាយុច្រើនជាងនេះនឹងហេសៗ

គ៖ ទៅពឹងគេទៅ

ក៖ ចាស!!

ខ៖ ទៅរំពឹងគេណាទៀត។

គ៖ ហើយចាស់ចឹងហើយនៅប្រឹងធ្វើការអីទៀត។

ខ៖ ហឹងឯកុំមកមើលងាយអញហេសៗ

ក៖ ចាស!កត់ៗវាបានពេញបំពង់ដៃរនឹងអ៊ុំ។

ខ៖
ចាស!នឹងហើយយើងចេះតែរកទៅទាន់យើងអាចនឹងរកបានបន្តិចទៀតទៅមានកូនណាគេណាទៀតទៅវានៅមិនទាន់ធម្មតាទេហាហ

គ៖
តិចទៀតនឹងគាត់ទៅនាំចូលផលិតផលបុរាណយកមកស្រុកខ្មែរហើយយករបស់ពីខ្មែរទៅចិនចឹងទៅ។

ខ៖ ហឺសៗៗ

ក៖ ចាស!ហើយនេះគឺជាបំណងប្រាថ្នារបស់អ៊ុំ។

ខ៖ នឹងហើយ

ក៖ ហើយបន្ទាប់មកសំរាប់ផ្ទះនេះផ្ទាល់តែម្តងអ៊ុំបានសាងសងឡើងនឹងនៅក្នុងឆ្នាំណាដែរ?

គ៖ ហឺស!

ខ៖ កសាងនឹងវាវាងឡើងយូរដែលហើយនឹង។

ក៖ ចឹងកាលកសាងនឹងអ៊ុំបានធ្វើឡើងនៅក្នុងឆ្នាំណាដែរ?

ខ៖ វាយូរហើយ

ក៖ ចាស!ហើយការសាងសងនឹងផ្ទះនឹងឡើងមានជាម៉ូតអ្វីដែរ?

ខ៖ វាមិនបាននឹងដឹងថាវាកសាងនឹងជាម៉ូតអីនោះទេកាលនឹងចេះតែជួលគេធ្វើទៅហីសៗៗ

ក៖ អូអ៊ុំជួលគេធ្វើន៎អ៊ុំ?

ខ៖ នឹងហើយ

ក៖ ចឹងអស់ប្រហែលជាប៉ុន្មានដែរទៅ?

ខ៖
កាលនឹងឈ្នួលគេនឹងមានតែប៉ុន្មានរយទេកាលនឹងនោះជួលគេនឹងសំរាប់ធ្វើនឹងផ្ទះរបស់ខ្ញុំនឹងធ្វើបានក្នុងលុយតែ៧០០០ដុល្លានោះទេកាលនឹងខ្ញុំនោះ។

ក៖ ចាស!!

ខ៖ ហើយកាលនឹងនោះខ្ញុំវាបានហត់នើយណាស់កាលនឹងខ្ញុំទំរាំតែនឹង
បានប៉ុនេសនោះពេលនឹងណាខ្ញុំនឹងវាត្បាញចឹងទៅហើយកូនៗនឹងវាបានជួយត្បាញអីចឹងដែលទៅហើយកាលនៅពីដើមនឹងណាខ្ញុំបានទៅម៉ៅអំពៅពីគេយកទៅលក់ទៀតទៅវាអត់នេះទេកាលនឹងខ្ញុំ២នាក់ប្តីរបស់ខ្ញុំហើយនឹងកូនៗរបស់ខ្ញុំនឹងទៅនេះ
ចឹងទៅដូចថាបានទៅដល់ចំការគេហើយនឹងបានធ្វើការម៉ោងចំការអំពៅគេនឹងថាបាន២លានទៅ៣លានចឹងទៅហើយពេលនឹងវាបានចំណេញបាន៤ទៅ៥លានអីដែលចឹងទៅណាកាលនឹងគ្រាន់តែខ្ញុំនឹងវាមានប្រាជ្ញាអីចឹងទៅកាលនឹងហើយក៏កុំអីនឹងខ្ញុំវាមិនទៅបានប៉ុណ្ណឹងនោះដែរ

ក៖ ចាស!!

ខ៖
ហើយកាលនឹងបើតាមកាលពីមុនមកនឹងខ្ញុំវាក្រនឹងខ្ញុំមានទៅបានម្តាយឪពុកណាគាត់មានជួយចែកកេរ្តិ៍អីទេហើយបើនិយាយពីខាងប្តីរបស់ខ្ញុំនឹង

ក៖ ចាស!!

ខ៖ ហើយបើនិយាយពីខាងប្តីរបស់ខ្ញុំនឹងគឺថាចប់តែម្តង
ចប់ម៉ងហើយនិយាយទៅខោអាវកាលនឹងមានតែមួយកំផ្លេគត់តែម្តងសំរាប់ខាងប្តីខ្ញុំនឹងខ្ញុំប្រាប់ទៅអារឿងនឹង។

ក៖
ចាស!ចឹងហើយដោយសារតែអ៊ុំមានគំនិតចឹងហើយបានជាអ៊ុំទាំង២នាក់ចាប់ដៃគ្នាចឹងទៅធ្វើការងាររកស៊ីបាន។

ខ៖
នឹងហើយកាលនឹងខ្ញុំបានទិញទូកទៅទិញអំពៅអីចឹងទៅខ្ញុំធ្វើការម៉ៅអីចឹងទៅយកទៅលក់ចឹងទៅ
ប៉ុន្តែប្តីរបស់ខ្ញុំនឹងគាត់មិនបានទៅរៀនសូត្រអីគាត់នឹងល្ងង់ណាស់ណាប៉ុន្តែកាលនឹងខ្ញុំបានទៅធ្វើការងារម៉ៅអំពៅគេនឹងនៅកណ្តាលថ្ងៃក្តៅអីនឹងគាត់មិនបានទៅឆ្លៀតនេះអីទេកាលនឹងមានតែខ្ញុំនោះទេកាលនឹងគឺគាត់ធ្វើការលីអំពៅអីចឹងដែលកាលនឹងគាត់លីម្តងអីនឹង១០បាច់អីនឹងងាប់ហើយព្រោះអីកាលនឹងគាត់មានមានធំហើយនិយាយទៅនឹងវាធៀបទៅគាត់មានមាឌធំជាងអានោះទេនឹងហាហាហា។

ក៖ ចាស!ដល់ចឹងអ៊ុំប្រុសគាត់មានមុខរបរតែមួយនឹងទេន៎?

ខ៖
ចាសហើយកាលពីមុនមកនឹងប្តីខ្ញុំនឹងគាត់មានបានទៅដើរស៊ីឈ្នួលអោយគេចឹងថាស្អីក៏គាត់ធ្វើដែលកាលដែលយើងនឹងនៅកូនៗវានៅរាងតូចៗនោះ។

គ៖ គាត់រែកដីអោយគេទៅស៊ីឈ្នួលអោយគេទាំងមានការរែកអំពៅនឹង។

ខ៖ គាត់ប្តីរបស់ខ្ញុំនឹងគាត់ជាអ្នកដែលនឿយហត់ណាស់មិនមែនចេះតែថានោះទេ។

ក៖ ចាស!!

ខ៖
គាត់ជាអ្នកដែលហាត់តែដល់ពេលឥឡូវនឹងគាត់មិនសូវជាហាត់ប៉ុន្មាននោះទេព្រោះអីនឹងគាត់វារាងចាស់ហើយវារាងហាត់ហើយចឹងគាត់មានភាពហាត់នឿយនឹងយូរណាស់ទៅហើយចឹងហើយបានកូនៗគេជួយហើយសព្វថ្ងៃនឹងគាត់ដើរទៅជួយមួយនឹងអាកូនខ្ញុំពៅគេនឹងអាឈើអាអីចឹងទៅហើយគាត់គ្រាន់តែជាអ្នកអាទេណាចំណែកឯកូនរបស់ខ្ញុំនឹងគាត់គឺជាអ្នកដែលកាប់ចឹងទៅ។

ក៖ ការងារនឹងវាយ៉ាងម៉េចដែរទៅអ៊ុំ?

គ៖ ការងារនឹងគាត់គឺជាអ្នកដែលកាប់ឈើដួលរលំហាហា

ក៖ ហាហា

ខ៖
គេដូចថាគេជួលអោយយើងនឹងទៅកាប់ដើមស្វាយអីចឹងទៅគេចឹងទៅហើយពេលដែលយើងទៅរំលុមដើមអោយគេចឹងទៅយើងគិតពីគេប៉ុន្មានចឹងទៅ។

គ៖ ដូចគេមិញគេបានមករកឯណោះ។

ខ៖ ចឹងវាចឹងណាដូចជាដើមឈើអានេះអីនឹង។

ក៖ ចាស!ហើយអ៊ុំដូចថាក្នុង១ដើមនឹងគេបានគិតអោយយើងបានប៉ុន្មានដែរ?

ខ៖
អានឹងគេមើលតាមនេះដែលនឹងដូចជាដើមណាខ្លះចឹងទៅគេបានគិតអោយយើង២០០០០រ ៣០០០០រ ៤០០០០រទៅ៥០០០០រអីចឹងដែលនឹងទៅតាមដើមឈើដែល។

ក៖ ចាស!!

ខ៖
ហើយទៅតាមតំរូវការរបស់គេដូចថាពេលខ្លះចឹងទៅដើមឈើនឹងគេចង់អោយនឹងនឹងគ្រាន់តែអា គ្រាន់តែជ្រែក គេអោយយើងនឹងពុះអោយគេអីចឹងដែលនឹង។

ក៖ ចាស!ចឹងគឺអាស្រ័យទៅលើដើមឈើ

ខ៖ ចាស!នឹងហើយ

ក៖
ថាវាមានទំហំប៉ុន្មានហើយគេចង់អោយយើងធ្វើយ៉ាងម៉េចហើយចឹងយើងក៏និយាយប្រាប់គេអំពីតំលៃ?

ខ៖ ចាស!នឹងហើយតាមនឹងហើយនឹងហើយ
ហើយនិយាយថាបើសព្វថ្ងៃនឹងបានកូនខ្ញុំនឹងវាបានទៅនឹងបានលុយ៥០០០០រទៅ៦០០០០រទៅ៧ទៅ៨០០០០រនៅក្នុង១ថ្ងៃអីចឹងទៅហើយដំពេលថ្ងៃអាទិត្រអីនឹងវាដើរលេងអីចឹងទៅ។ សព្វថ្ងៃនឹងវារាងបានធូរអីនឹងវាចឹងដែលទេ។

ក៖ចឹងកូនៗរបស់អ៊ុំដូចថាពួកគាត់បានបញ្ចប់ការសិក្សាបានគ្រាប់គ្នាអស់ហើយនេហ៎អ៊ុំ?

ខ៖ ចាស!!

ក៖ ចឹងអត់មានកូនណាដែលអត់បានរៀននោះទេ?

ខ៖
ចាស!បានរៀនទាំងអស់គ្នានឹងតែគ្រាន់តែថាកូនប្រុសខ្ញុំអាមួយនោះដែលថាគេបានទៅធ្វើការងារនៅប្រទេសកូរ៉េនឹងពេលនឹងវាបានរៀនត្រឹមតែថ្នាក់ទី១១ទេអានឹងក្រៅពីនឹងកូនៗផ្សេងៗទៀតនឹងគេបានរៀនចប់អស់ហើយ
ព្រោះអីកូនអាប្រុសនឹងវាថាម្ដាយឯងអត់ក្រចឹងចាំខ្ញុំទៅរៀនភាសាកូរ៉េទៅហើយចឹងវាក៏ទៅរៀនចឹងទៅហើយពេលនឹងវាមានសំណាងដែលកាលនឹងនោះដែលថាវារៀនបានតែម្ដងទេហើយក៏ប្រឡងទៅក៏បានជាប់នឹងគេចឹងទៅ
ពេលនឹងវាជាប់ហើយនឹងវាបានទៅតែម្ដងបើមើលខ្លះចឹងទៅគេទៅរៀនឡើង២ទៅ៣ដងឯនោះ។

កៈ ចាស!គាត់ឆាប់នឹងចាប់បាន។

ខៈ នឹងហើយឪ

កៈ ចឹងគាត់បានចេះរកលុយនឹងរកស៊ីតែម្តង។

ខៈ នឹងហើយហាហា

កៈ
ចាស!ចឹងជាចុងក្រោយតើអ៊ុំនឹងមានពាក្យពេជ្រអ្វីដើម្បីនឹងធ្វើការផ្តែផ្តាំផ្ញើរដល់កូនចៅអ៊ុំជំនាន់ក្រោយនឹងអ្នកជំនាន់ក្រោយដែលគេបានស្តាប់សំលេងរបស់អ៊ុំនឹងណា។

ខៈ ហេសៗៗ
អោយតែវានឹងចេះគិតទៅកុំអោយតែវានឹងចេះភ្លើតភ្លើនទៅដើរលេងដើរសើចចឹងហើយដូចជាកូនរបស់ខ្ញុំនឹងវាដើរដែរតែគ្រាន់តែវាដើរនឹងថាខ្ញុំវាខ្ជិលទៅថាអីអោយវាអោយវានឹងបានដើរអីខ្លះចឹងទៅ។

កៈ ចាស!!!

គៈ កូនបងនឹងកូនពៅពេលដើរទៅណាជាមួយគ្នាពេលដែលដើរទៅនឹងវាបានចែកផ្លូវគ្នា។

ខៈ ហឺសៗៗ!

គៈ វាចឹង

ខៈ
វាសំណាងហើយឯបានទិញម៉ូតូអោយវានឹងជិះហើយនឹងប្រើវាអោយជូនយើងនឹងទៅភ្នំពេញអីនឹងវាមិនទៅចង់ជូនឯងអីនឹងទៅផងនឹង។

កៈ មិចចឹងអ៊ុំព្រោះតែវានៅឆ្ងាយពេកឬក៏ម៉េច?

ខៈ វានឹងវាខ្ជិលចឹងណាបើពេលវាទៅចឹងទៅវាខាននៅឯនេះចឹង។

កៈ កូនអ៊ុំនឹងគាត់មានឈ្មោះអីគេដែរគាត់នឹង?កូនពៅនឹង

ខ៖ កូនអាពៅនឹងវាមានអាយុជិត៣០ឆ្នាំហើយហឺសៗ

ក៖ ហឹស!!

ខ៖ វាមានអាយុបាន២៨ឆ្នាំហើយតែបើអាមួយទៅខាងប្រទេសកូរ៉េនឹងវាមានអាយុឡើង៣០ហើយ។

ក៖ ហើយចឹងគាត់បានទៅយូរដែលហើយចឹងណាអ៊ុំនេស?

ខ៖ គេបានទៅនឹងប្រហែលជាបាន៨ឆ្នាំហើយ។

ក៖ ព្រោះមើលបើថាគាត់មានបានរៀនត្រឹមថ្នាក់ទី១១នឹងហើយទៅគឺគាត់ប្រហែលជាមានអាយុត្រឹមតែ១០ជាងអីនោះទេ ត្រូវទេអ៊ុំ? ព្រោះបើគាតបានរៀនទី១១នឹងហើយទៅហើយនឹងពេលនឹងកាលដែលគាត់នឹងបានរៀនថ្នាក់ទី១១នឹងតើគាត់មានអាយុបានប៉ុន្មានឆ្នាំដែរកាលនឹង?

ខ៖ ហឺ!កាលកាលនឹងវាមានអាយុជាងព្រោះអីកាលនឹងវាបានឈប់យូរដែលហើយនឹងកូនប្រុសរបស់ខ្ញុំនឹងនោះ។

ក៖ ចឹងនឹងឥឡូវនឹងគាត់ប្រហែលជាមានអាយុប្រហែលជា២០ទៅ២៥អីនឹងបន្តិចបន្តួចអីចឹងដែរនឹង?

ខ៖ នឹងហើយ

ក៖ ចាស!ចឹងអ៊ុំមានពាក្យដើម្បីនឹងចង់និយាយជាចុងក្រោយដើម្បីនឹងធ្វើការផ្តាំផ្ញើរដើម្បីនឹងចង់និយាយទៅអ្នកដែលគេបានស្តាប់សំលេងមយនឹងដែលជាសំលេងរបស់អ៊ុំដូចថាក្នុងពេលឥឡូវនឹងអ៊ុំចង់ប្រាប់គេថាជេកៗចឹងណាពីមួយទៅមួយទៀតចឹងតើអ៊ុំមានពាក្យអ្វីដែរឬទេ?

ខ៖ ហឹស!ខ្ញុំវាមិនសូវជាចេះនិយាយដែរទេហេសៗៗៗ។

ក៖
ដូចជាពាក្យដែលអ៊ុំចង់អោយអ្នកជំនាន់ក្រោយទៀតនឹងគាត់បានស្តាប់ហើយគាត់ត្រូវធ្វើយ៉ាងត្រូវធ្វើអីឬក៏មានអ្វីបន្ថែមទៀតឬក៏មានពាក្យអ្វីដែលបានចេញអំពីចិត្តរបស់អ៊ុំផ្ទាល់តែម្តងនឹងណា?

ខ៖
ហឹយ!គិតតែអោយក្មេងជំនាន់ក្រោយនឹងវាបានខំប្រឹងរៀននឹងខំប្រឹងសូត្រទៅហើយរកស៊ីតែទៀងត្រង់ទៅកុំអោយតែដើរខុសច្បាប់ទៅបានហើយ បានហើយទៅហាហា

ក៖ ចាស!!!

ខ៖ ខ្ញុំគ្មានពាក្យពេជ្រអ្វីនោះទេខ្ញុំមិនសូវជាចេះនិយាយផង។

ក៖ អត់ចេះនិយាយទៀតអ៊ុំឡើងនិយាយបានច្រើនហើយប៉ុណ្ណឹងនោះហេសៗ

ខ៖ ហឹសៗ!

ក៖
ចាស!ចឹងជាចុងក្រោយនឹងខ្ញុំសូមអរគុណអ៊ុំច្រើនដែលបានចំណាយពេលដើម្បីនឹងអោយខ្ញុំធ្វើការសំភាសន៏អ៊ុំស្រីនៅជីវៈប្រវត្តិរបស់អ៊ុំ បទពិសោធន៏ដែលអ៊ុំបានធ្លាប់ជួប
នឹងព្រមទាំងក្រុមគ្រួសារ
ចាសហើយចឹងខ្ញុំសូមការអនុញ្ញាតសំរាប់ការសំភាសន៏មួយនឹងហើយនឹងដើម្បីយកសំលេងមួយនឹងយកទៅដាក់នៅក្នុងខាងវេសាយសាលាBYU
នៅខាងសហរដ្ឋអាមេរិកដើម្បីអោយគាត់ធ្វើការចង់ក្រង់ឯសារទុកណាអ៊ុំ
ចាសចឹងអរគុណអ៊ុំច្រើនដែលថ្ងៃនេះបានចំណាយពេលដើម្បីនឹងអោយខ្ញុំធ្វើការសំភាសណ៏។ហើយក៏សូមជូនពរអ៊ុំ

ខ៖ ចាស!!!

ក៖ នៅក្នុងឆ្នាំនេះទាំងសុខភាព ក្រុមគ្រួសារមានសុភមង្គលទាំងអស់គ្នាអ៊ុំ។

ខ៖ ចាស!ហាហា